ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសភាពាណិជ្ជកម្មខេត្តព្រៃវែង

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦៩៥ / ០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបបនិងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- តាមសំណើរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

www.pheakdeylaw.com

## សម្រេច

**មាត្រា ១.-**

បង្កើតសភាពាណិជ្ជកម្មមួយសំរាប់ខេត្តព្រៃវែង ហៅថាសភាពាណិជ្ជកម្មខេត្តព្រៃវែង ព្រំដែនមណ្ឌលសភាពាណិជ្ជកម្មខេត្តព្រៃវែង គឺកំណត់តាមព្រំដែនខេត្តព្រៃវែង ។

**មាត្រា ២.-**

សភាពាណិជ្ជកម្មខេត្តព្រៃវែង មានសមាជិកជ្រើសតាំងចំនួនដប់ប្រាំរូប (១៥រូប) ដែលជ្រើសរើសតាមការបោះឆ្នោត ។ សភាពាណិជ្ជកម្មខេត្តព្រៃវែង អាចបង្កើតគណៈកម្មការផ្សេងៗតាមការចាំបាច់ ដើម្បីអភិវឌ្ឍប្រភេទអាជីវកម្មនីមួយៗ ។

**មាត្រា ៣.-**

តាមសំណើរបស់ប្រធានសភាពាណិជ្ជកម្មខេត្តព្រៃវែង ក្រសួងពាណិជ្ជកម្មត្រូវកំណត់តាមប្រកាសនូវសមាជិកទីប្រឹក្សាស្របតាមលក្ខណដែលមានចែងក្នុងមាត្រា ០៥ នៃច្បាប់ ស្តីពី សភាពាណិជ្ជកម្ម ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីរដ្ឋលេខាធិការក្រសួងពាក់ព័ន្ធ អភិបាលខេត្តព្រៃវែង និងប្រធានសភាពាណិជ្ជកម្មខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០៤

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ដូចមាត្រា ៥
- សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន
សម្តេច នាយករដ្ឋមន្ត្រី សូមហត្ថលេខា
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

ហ៊ុន សែន

www.pheakdeylaw.com